**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ ២៦៤៦ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **សក់ សេដ្ឋា** | រដ្ឋលេខាធិការប្រចាំការ | ប្រធាន |
| ២. | ឯកឧត្តម | **ហ៊ុយ ទណ្ណៈ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម នាយឧត្តមសេនីយ៍ | **ឆោំ តត្ថិ** | អគ្គលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |

| | | | | |
|---|---|---|---|---|
| ៤. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ហោ សំអាត** | អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋាន-ព័ត៌មានវិទ្យា | សមាជិក |
| ៥. | ឯកឧត្តម | **ឆាន់ ចន្ទសុរគ្គី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| ៦. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឈឹម ផាន់នារ:** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារនិង-ហិរញ្ញវត្ថុ | សមាជិក |
| ៧. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ ផាសេនា** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានជនបរទេស-មិនមែនអន្តោប្រវេសន៍និងបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| ៨. | ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ | **នោ ពន្លក** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារ | សមាជិក |
| ៩. | ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឆន ឡាធី** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១០. | ឯកឧត្តម ឧត្តមសេនីយ៍ទោ | **អ៊ុកចាយ បញ្ញារិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ១១. | ឯកឧត្តម | **ហួត លេនីន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១២. | លោកឧត្តមសេនីយ៍ត្រី | **ឈុន ធន្ណា** | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា-នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| ១៣. | លោកឧត្តមសេនីយ៍ទោ | **ហាយ មករា** | អនុប្រធាននាយកដ្ឋានស៊ើបការណ៍ខាងក្រៅ និង-បច្ចេកទេស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៤. | លោកឧត្តមសេនីយ៍ត្រី | **ស៊ុយ ឈឹម** | នាយករងវិទ្យាស្ថានព័ត៌មានវិទ្យានិងភាសាបរទេស-នៃបណ្ឌិត្យសភានគរបាលកម្ពុជា | សមាជិក |
| ១៥. | លោកវរសេនីយ៍ឯក | **ទុំ ធីណា** | សមាជិកក្រុមប្រឹក្សានីតិកម្ម | សមាជិក |

**ប្រការ២ .**_

ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ លើការងាររដ្ឋាភិបាលឌីជីថលក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងគ្រប់គ្រងគម្រោងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៅតាមបណ្តាអគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួង
- សហការជាមួយដៃគូពាក់ព័ន្ធ ទីប្រឹក្សា និងអ្នកជំនាញតាមការចាំបាច់ ដើម្បីរៀបចំគោលនយោបាយផែនការមេបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពធនធានមនុស្ស
- គ្រប់គ្រងការធ្វើសមាហរណកម្មតភ្ជាប់រវាងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន របស់ក្រសួងមហាផ្ទៃ ជាមួយប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៃបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា

- គ្រប់គ្រងការធ្វើបច្ចុប្បន្នភាព វាយតម្លៃគុណភាពប្រព័ន្ធ និងសម្ភារៈបច្ចេកទេស បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឲ្យសមស្របតាមស្ថានភាពរីកចម្រើននៃបច្ចេកវិទ្យាពិភពលោក បម្រើដល់ការងារជំនាញ និងការងារផ្តល់សេវាសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាព
- រៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដើម្បីធានាដល់ការងារអនុវត្តប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ការងាររដ្ឋាភិបាលឌីជីថល ពលរដ្ឋឌីជីថល និងធុរកិច្ចឌីជីថល ក្របខ័ណ្ឌក្រសួងមហាផ្ទៃ
- រៀបចំរបាយការណ៍អំពីលទ្ធផលការងារតាមដំណាក់កាលនីមួយៗ ជូនរដ្ឋមន្ត្រីដើម្បីជូនជ្រាប ឬ/និងស្នើសុំមតិដឹកនាំតាមការចាំបាច់ ។

**ប្រការ៣ ._**

ក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលដឹកនាំដោយ នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ។

**ប្រការ៤ ._**

លេខាធិការដ្ឋាន នៃក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សិក្សា រៀបចំ តាមដាន ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងអាទិភាពបច្ចេកវិទ្យាឌីជីថលនានាតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ និងរាយការណ៍ជូនក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ពិនិត្យ និងសម្រេច
- គ្រប់គ្រង តាមដាន ធ្វើបច្ចុប្បន្នភាពកិច្ចការងារពាក់ព័ន្ធនឹង រដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ចឌីជីថល សង្គមឌីជីថល វិទ្យាសាស្ត្រ បច្ចេកវិទ្យា ឬនវានុវត្តន៍នានារបស់ក្រសួងមហាផ្ទៃ ជូនក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ
- គ្រប់គ្រង និងតាមដានការអនុវត្តផែនការសកម្មភាពគម្រោង កិច្ចសន្យាផ្គត់ផ្គង់គម្រោង ការធានាគុណភាពសុវត្ថិភាព និងគ្រប់គ្រងហានិភ័យពាក់ព័ន្ធការងារអនុវត្តតាមផែនការយុទ្ធសាស្ត្រ
- សហការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារអនុវត្តគម្រោងតាមផែនការសកម្មភាព ដែលបានអនុម័តដោយក្រសួងមហាផ្ទៃ ដើម្បីធានាបានការអនុវត្តគម្រោងទទួលបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់
- សម្របសម្រួលក្នុងការរៀបចំគោលនយោបាយបច្ចេកវិទ្យាឌីជីថល នីតិវិធីអនុវត្តការងារ និងការងារគ្រប់គ្រងការផ្លាស់ប្តូរ (Change Management) ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- រៀបចំផែនការបណ្តុះបណ្តាល និងកសាងសមត្ថភាពដើម្បីទ្រទ្រង់ដល់ដំណើរការអនុវត្តគម្រោង និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលប្រកបដោយប្រសិទ្ធភាព និងចីរភាព
- គ្រប់គ្រងការងារសមាហរណកម្មតភ្ជាប់ប្រព័ន្ធបណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសន្តិសុខព័ត៌មាន
- តាមដានការអនុវត្តកម្មវិធីថែទាំឧបករណ៍សម្ភារៈបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន តាមប្រតិទិនកំណត់ និង/ឬតាមតម្រូវការបច្ចេកទេសរបស់អង្គភាពចំណុះក្រសួងមហាផ្ទៃ ដែលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ។

**ប្រការ៥ ._**

- អនុប្រធាន និងសមាជិក នៃក្រុមការងាររដ្ឋាភិបាលឌីជីថល បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្រសួងមហាផ្ទៃ ត្រូវចូលរួមកិច្ចប្រជុំ និងបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានក្រុមការងារ
- ក្រុមការងារអាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធផ្សេងទៀត ឱ្យចូលរួមប្រជុំក្នុងករណីចាំបាច់
- អនុប្រធាន និងសមាជិក នៃក្រុមការងារលេខាធិការដ្ឋាន ត្រូវចូលរួមកិច្ចប្រជុំ និងបំពេញការងារក្រោមការចាត់ចែងរបស់ប្រធានលេខាធិការដ្ឋាន
- ប្រធានលេខាធិការដ្ឋានអាចអញ្ជើញអ្នកជំនាញពាក់ព័ន្ធផ្សេងទៀត ឱ្យចូលរួមប្រជុំក្នុងករណីចាំបាច់
- ប្រធានលេខាធិការដ្ឋាន មានសិទ្ធិចេញសេចក្តីសម្រេចក្នុងការបង្កើតផ្នែកការងារតូចៗតាមការចាំបាច់ ដើម្បីជំរុញដល់ការអនុវត្តតាមគម្រោងឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ។

**ប្រការ៦ ._**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកសុ្ភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៦ កើត ខែប.សាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
(ដើម្បីជូនជ្រាប)
-ឯកសារ កាលប្បវត្តិ